# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

*************

**តុលាការកំពូល**

---

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៦២

ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

សាលដីកា

លេខ : ២២២

ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០១

## នាមអង្គព្រះមហាក្សត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០១

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ជីវ កេង ជាចៅក្រម

៣- លោក គង់ ភិរុណ ជាចៅក្រម

៤- លោក ប្រាក់ គិមសាន ជាចៅក្រម របាយការណ៍

៥- លោក សោម សិរីវុឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា លេខ ៤៤ " ឈ " ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០១ នៃ សំណុំរឿងរដ្ឋប្បវេណី លេខ ៥៧៨ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ លោក ឯម ប៊ុនថា ( តំណាងដោយលោកមេធាវី ទូច-ឆេងតិច អាយុ៣៣ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ១២៨ ផ្លូវ ៤៣២ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ពីវ គួយ " រ " ម្តាយឈ្មោះ ទូច អ៊ីវ " រ " ប្រពន្ធ ឈ្មោះ ទូច សុធាវី ។

- និងចុងបណ្តឹងសាទុក្ខឈ្មោះ ជា ប៊ូរ៉ាត ភេទប្រុស អាយុ៤៧ ឆ្នាំ ជាតិខ្មែរ មុខរបរ អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងការបរទេស ( តំណាងក្រសួងការបរទេស ) ទីលំនៅផ្ទះលេខ ៨៧ ផ្លូវមុន្នីរ៉េត សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ ជា ថ្មី " រ " ម្តាយឈ្មោះ លន់ ស៊ីឆេង " រ " ។

- អំពីវិវាទ : សុំរំលាយកិច្ចសន្យាជួលអសង្ហារិម ចុះថ្ងៃទី ០១-០១-៩៥ និង ទាមទារ ប្រាក់ឈ្នួល ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៣៤ ចុះថ្ងៃទី ២០ខែ មេសា ឆ្នាំ ២០០១ របស់ លោក ទូច ឆេងតិច មេធាវី និង តំណាងឱ្យភាគី ឯម ប៊ុមថា ប្តឹងមិនសុខចិត្ត ពីសាលដីកា រដ្ឋប្បវេណី លេខ ៤៤

"ឈ" ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១៤-៥-៩៩ របស់ក្រសួងការបរទេសថា ខ្លួនប្តឹងសុំរំលាយកិច្ចសន្យា ជួលអសង្ហារិម និងទារសំណងប្រាក់ឈ្នួលព្រមទាំងការប្រាក់យឺតយ៉ាវ ពីឈ្មោះ ឯម ប៊ុនថា ដោយហេតុថា ឈ្មោះនេះ មិនគោរព តាមកិច្ចសន្យា ចុះថ្ងៃទី ០១-០១-៩៥ ។

បានឃើញ សាលក្រមលេខ ០៨ "ឆ" ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ១៤-០៥-៩៩ របស់ឯកឧត្តម ហោ ណាំហុង ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥-១១-៩៩ របស់លោក ហោ ណាំហុង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១២-០៧-៩៩ របស់លោក ឯម ប៊ុនថា ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី ១៥-០២-២០០០ របស់លោក ទូច ឆេងតិច ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយខុសពីគតិច្បាប់ ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០រៀល សរុប ៧០០០រៀល ដែលឈ្មោះ ទូច ឆេងតិច បានបង់រួចហើយ ។

៦- រំលាយកិច្ចសន្យាជួលអសង្ហារិមនិង អាគារសាខាស្ថិតនៅឡូត៍លេខ ០៨ ផ្លូវសម្តេចល្វាឯម ច្រកមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ រវាងក្រសួងការបរទេស និង កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលតំណាងដោយលោក ស៊ឹម សួង ប្រធាននាយកដ្ឋានកិច្ចការទូទៅក្រសួងការបរទេស និង លោក ឯម ប៊ុនថា ចោលជាអសារបង់ និង ប្រគល់អសង្ហារិម ខាងលើជូនក្រសួងការបរទេស កាន់កាប់វិញ ចាប់ពីថ្ងៃនេះតទៅ តាមមាត្រា ១០៧ នៃច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវ ក្រៅកិច្ចសន្យា ។

៧- បង្គាប់ឱ្យឈ្មោះ ឯម ប៊ុនថា បង់ថ្លៃឈ្នួល ដែលនៅជំពាក់ក្រសួងការបរទេស ចំនួន ៤៦០៤០$US គិតរហូតដល់ថ្ងៃទី ២៩-០២-២០០០ តាមមាត្រា ១០៥ នៃ ច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា បើឈ្មោះ ឯម ប៊ុនថា គ្មានប្រាក់សង ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរងរះត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់តាមច្បាប់ស្តីពីនីតិវិធី អនុវត្តសាលក្រមរដ្ឋប្បវេណី ។

៨- បង្គាប់ឱ្យឈ្មោះ ឯម ប៊ុនថា បង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបណ្តឹងក្តី និង ពន្ធហ៊ឹងចំនួន ១៨០០៛, រង្វាន់ក្រឡាបញ្ជីកាន់ហិប ២០០៛, រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ សរុប ៧០០០រៀល

ប្រាក់នេះ បានកាត់យកពីប្រាក់ ៧០០០$ ដែលដើមចោទបានបង់ទុកជាស្រេច កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយ សងប្រាក់ ៧០០០$ ឱ្យដើមចោទវិញ និង បង្គាប់ឱ្យបង់ពន្ធសមាមាត្រ ១% លើប្រាក់ ៤៦០៤០$ ស្មើនឹង ៤៦០$ ប្រាក់ពន្ធសមាមាត្រនេះ ត្រូវបង់ចូលថវិកាជាតិចំនួន ៨០% ស្មើនឹង ៣៦៨$ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ចំនួន ២០% ស្មើនឹង ៩២$ ។

៥- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខតំណាងគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ លេខ ០៩ " រ " ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ របស់លោកមេធាវី ទូច វេងតិច ប្តឹងមិនសុខចិត្ត នឹង សាលក្រមលេខ ០៨ " រ " ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ៤៤ " ឈ " ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១ របស់ សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តី សំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍ របស់មេធាវី ទូច វេងតិច ចុះថ្ងៃទី ២០-៤-២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយខុសនឹង អង្គច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ០៨ " រ " ចុះថ្ងៃទី ២៩-០២-២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- វិបត្តិសប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ីង២.៥៥០រៀល , រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ១៣៤ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០១ របស់លោកមេធាវី ទូច វេងតិច និង ជាតំណាងឱ្យលោក ឯម ប៊ុនថា ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណី លេខ ៤៤ " ឈ " ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ១២-១០-២០០១ របស់លោកមេធាវី ទូច វេងតិច តំណាងឱ្យលោក ឯម ប៊ុនថា .

បានឃើញ សារណាតប ចុះថ្ងៃទី ១៥-១០-២០០១ របស់លោក ជា ប៊ូរ៉ាត

បានស្តាប់ របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

- តំកល់សំណុំរឿងទុកជាបានការពេញទាំងមូល ។

ស្នូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

ក្រឡាបញ្ជី អានសារណារបស់លោក ឯម ប៊ុនថា

បានស្តាប់ចម្លើយរបស់ឈ្មោះ ជា ប៉ូរ៉ាត ឆ្លើយថា : សុំឱ្យតុលាការរំលាយកិច្ចសន្យា ជួល អសង្ហារឹម និង អាគារសាខា ស្ថិតនៅផ្ទះលេខ ០៨ ផ្លូវសម្តេចឈ្វាឯម ច្រកមហាវិថីព្រះនរោត្តមរវាងក្រសួងការបរទេស និង លោក ឯម ប៊ុនថា ចោលជាអសារបង់ ។

សុំឱ្យលោក ឯម ប៊ុនថា បង់ថ្លៃឈ្នួលជំពាក់មកក្រសួងការបរទេស ។

លោកមេធាវី ទូច ឆេងតិច តំណាងឱ្យលោក ឯម ប៊ុនថា បានធ្វើសេចក្តីសន្និដ្ឋានថា :

កិច្ចសន្យាតឹ មានរយៈពេល ១៥ឆ្នាំ គឺចាប់ពីថ្ងៃទី ០១-០១-១៩៩៥ ដល់ថ្ងៃទី ៣០-១២-២០០៩ នៅពេលនោះ តំលៃជួលគឺ ២៣០០ $ ( ពីរពាន់បីរយដុល្លាអាមេរិក ) ក្នុងមួយខែលោកឧកញ៉ា ឯម ប៊ុនថា បានអនុវត្តតាមកិច្ចសន្យាបង់ប្រាក់ ឱ្យក្រសួងការបរទេសមករហូតដល់ឆ្នាំ ១៩៩៧ មានសភាពការណ៍សង្គ្រាមក្នុងប្រទេស ( ថ្ងៃទី ៥, ៦ កក្កដា ឆ្នាំ ១៩៩៧ ) ទើបគាត់ផ្អាកការរកស៊ី និង បង់ប្រាក់ឱ្យមួយរយៈ ពីព្រោះគាត់បានចេញទៅបរទេស ។

ក្រោយមកនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ក្រសួងការបរទេស បានចេញលិខិតទារប្រាក់ពីគាត់ ដោយមានការឯកភាពពីរដ្ឋមន្ត្រីឱ្យបង់តំលៃតែ ១០% ប៉ុណ្ណោះ ក្នុងមួយខែ ស្មើនឹង ( ២៣០$ ក្នុងមួយខែ ) ។

តាមច្បាប់កិច្ចសន្យាដែលអាចរំលាយកិច្ចសន្យាបានលុះត្រាតែគូភាគីណាមួយមានកំហុស ។ ប៉ុន្តែនៅក្នុង កិច្ចសន្យាជួលអចលនវត្ថុរវាងលោក ឧកញ៉ា ឯម ប៊ុនថា និង ក្រសួងការបរទេស ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ នោះ ត្រង់ប្រការទី៧ ចំណុច " ខ " ស្តីពីការបដិសេធកិច្ចសន្យា និង ប្រការទី៨ ស្តីពីពេលមានវិវាទ " សិទ្ធិ និង ការដោះស្រាយវិវាទ " គឺភាគីទាំងពីរត្រូវពិភាក្សាគ្នាដោះស្រាយវិវាទគ្នា ជាលក្ខណៈមិត្តភាព ដោយឈរលើស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។ ម្យ៉ាងទៀត ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបានរវាងគ្នា ការវិវាទនេះ នឹង ត្រូវបញ្ជូនទៅបង្កើតអាជ្ញាកណ្តាលមួយ ដើម្បីដោះស្រាយមុនពេលបញ្ជូនទៅតុលាការ ។ ហេតុដូចនេះ ក្រសួងការបរទេស តំណាងឱ្យលោក ជា ប៉ូរ៉ាត ពុំបានគោរពតាមកិច្ចសន្យារបស់ខ្លួនត្រង់ប្រការ ៧-៨ នោះឡើយ ។

ខ្ញុំបាទសូមសំណូមពរពីឯកឧត្តម មេត្តាបង្វិលសំណុំរឿងក្តីនេះ ទៅសាលាឧទ្ធរណ៍ ដើម្បីឱ្យគូភាគីកែប្រែកិច្ចសន្យាជាថ្មី និង សាលាឧទ្ធរណ៍បន្តចាត់របៀបអង្កេតមើលសភាពការណ៍ជាក់ស្តែង ដែលកំពុងជួសជុលកែលំអ ចំពោះសណ្ឋាគារ និង ការដាក់ទុនបន្ថែមទៀតអស់ប្រាក់ជាច្រើន ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់សារណារបស់តំណាងចុងចម្លើយ និង ចម្លើយរបស់តំណាងដើមចោទ និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី ចុងចម្លើយ ។
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៣៤ ចុះថ្ងៃទី ២០-៤-២០០១ របស់លោក ទូច ឆេងពិច ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា១៤ នៃ ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី។

- យល់ឃើញថា ការលើកឡើងរបស់លោក ទូច ឆេងពិច តំណាងឱ្យលោក ឯម ប៊ុនថា ក្នុងសារណាចុះថ្ងៃទី ១២-១០-២០០១ ថា តំណាងក្រសួងការបរទេស លោក ជា ប៊ូរ៉ាត ពុំបានគោរពតាមកិច្ចសន្យាត្រង់ប្រការ ៧-៨ និង ពុំបានគោរពតាមកិច្ចសន្យាក្នុងករណី ពេលមានប្រធានសក្តិ សង្គ្រាមកើតឡើង និង ពុំបានពិភាក្សាគ្នាដោះស្រាយ ពុំបានបង្កើតអាជ្ញាកណ្ដាល គឺបែរជាប្ដឹងមកតុលាការ ដើម្បីសុំរំលាយកិច្ចសន្យា ដែលមិនទាន់ចប់នោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ ក្រសួងការបរទេស បានជូនដំណឹង លោក ឯម ប៊ុនថា តាមលិខិតអញ្ជើញលេខ ២៤៩-ហគ.កបទ.សអ ចុះថ្ងៃទី ១៩-០១-៩៩ លិខិតលេខ ១០៣៦ ហគ.កបទ.សអ ចុះថ្ងៃទី ០១-៣-៩៩ លិខិត១៦៧៤ ហគ.កបទ.សអ ចុះថ្ងៃទី ០៥-៤-៩៩ រួចហើយ ។ ប៉ុន្តែលោក ឯម ប៊ុនថា ពុំបានអញ្ជើញចូលទៅដោះស្រាយតាមការអញ្ជើញទេ។

+ លោក ឯម ប៊ុនថា ជាអ្នកជួលពុំបានគោរពតាមលក្ខខ័ណ្ឌ នៃ កិច្ចសន្យា ព្រមទាំងពុំបានបំពេញកាតព្វកិច្ច របស់ខ្លួនដូចមានចែងក្នុងប្រការ ៣ នៃ កិច្ចសន្យា ទោះបីក្រសួងការបរទេសបានបញ្ចុះតម្លៃថ្លៃឈ្នួលយកតែត្រឹម ១០% ក្នុងពេល និង ក្រោយពេលព្រឹត្តិការណ៍ ថ្ងៃទី ៥-៦ ខែ កក្កដា ឆ្នាំ ១៩៩៧ ក៏ដោយ ។

- យល់ឃើញថា លោកមេធាវី ទូច ឆេងពិច ជាតំណាងឱ្យលោក ឯម ប៊ុនថា បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ហើយលោកមេធាវី ក៏បានមកចូលរួមនាសវនាការនេះដែរ ប៉ុន្តែលោកបានដាក់ពាក្យសុំពន្យាពេលសវនាការ ដោយហេតុថា លោក ឯម ប៊ុនថា មានធុរៈ ចាំបាច់ និង ពុំទាន់បានទទួលដីកាកោះ ។ តុលាការកំពូលពុំអាចពន្យាពេលបានទេ ពីព្រោះពុំមានភស្តុតាងណា ថា លោក ឯម ប៊ុនថា ពិតជាមានធុរៈចាំបាច់មែន ហើយតំណាងមហាអយ្យការ ដែលមានភារកិច្ចការពារប្រយោជន៍សាធារណៈ របស់ដើមចោទ ក៏ពុំយល់ព្រមដែរ ។ ដូច្នេះតុលាការកំពូល ជំនុំជំរះ រឿងនេះកំបាំងមុខ ចាត់ទុកជាចំពោះមុខ លោក ឯម ប៊ុនថា ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៤ " ឈ " ចុះថ្ងៃទី ២៩-៣-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តីចំពោះមុខចំណោមក្រសួងការបរទេស និង**

**សហប្រតិបត្តិការអន្តរជាតិ កំបាំងមុខលោក ឯម ប៊ុនថា**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ ១៣៤ ចុះថ្ងៃទី ២០-៤-២០០១ របស់ លោក ទូច ឆេងតិច ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់ សាលដីការដ្ឋប្បវេណី លេខ ៤៤ " ឈ " ចុះថ្ងៃទី ២៩-៣-០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រ០០ ដែល លោក ជា ប៊ូរ៉ាត បានបង់ជូនគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤០០០រ០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រ០០ សរុប១៩.០០០រ០០ ហើយតម្រូវឱ្យលោក ឯម ប៊ុនថា សងប្រាក់ចំនួន ១៩.០០០រ០០ នេះ ទៅឱ្យលោក ជា ប៊ូរ៉ាត វិញ ។

បង្គាប់ឱ្យលោក ឯម ប៊ុនថា បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០១ ។